ព្រះរាជាណាចក្រកម្ពុជា

សាលាឧទ្ធរណ៍ភ្នំពេញ ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

**************

លេខ: ១៨ / ១០.០១.២០១១

សាលដីកា

លេខ: ៨០ ក្រ.III.ស/២៦.១០.២០១២

# ក្នុងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ:

<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>

លោក [redacted] [redacted] ជាប្រធាន

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted]

<u>ក្រឡាបញ្ជី</u>

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១៨ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ រវាង ៖

**ជនជាប់ចោទឈ្មោះ** [redacted] ដាយូសា ហៅ បូ ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ សាសនាអ៊ីស្លាម មុខរបរៈជាងឡាន កើតនៅខេត្តកំពង់ឆ្នាំង ទីលំនៅមុន [redacted] ភូមិសាមគ្គី សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] [redacted] (រ) ម្តាយឈ្មោះ [redacted] [redacted] (រ) ប្រពន្ធឈ្មោះ [redacted] គ្មានកូន ទោសពីមុនៈធ្លាប់ជាប់ពន្ធនាគារ១ឆ្នាំពីបទទិញលក់គ្រឿងញៀនខុសច្បាប់ ចាប់ខ្លួនថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១០, ឃុំខ្លួនថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០។

មានមេធាវីការពារ លោកស្រី [redacted] ម៉ងអ៊ាម ។

<u>ត្រូវចោទពីបទៈ</u> ប៉ុនប៉ងប្លន់ និងប្រើប្រាស់អាវុធហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២០ នៃច្បាប់

ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ុ ហៅ យាយង៉ា ភេទស្រី អាយុ៧៣ឆ្នាំ ជាតិខ្មែរ [redacted] បច្ចុប្បន្នរស់នៅ [redacted] ផ្លូវលេខ២០២ ក្រុម២១ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ជនរងគ្រោះឈ្មោះ [redacted] គន្ធា ភេទស្រី អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរៈសិស្ស បច្ចុប្បន្នរស់នៅផ្ទះលេខ០៨៥ ផ្លូវបេតុងទី១ ក្រុម២ ភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

## ៦ដំណើររឿងមានដូចតទៅៈ

កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង ៦ និង៣០នាទី ឈ្មោះ [redacted] គន្ធា ជិះម៉ូតូម៉ាកគុបពណ៌ទឹកប៊ិច ចេញពីផ្ទះទៅប្រឡងនៅវិទ្យាល័យព្រះស៊ីសុវត្ថិ, បានចំងាយប្រហែល១០០ម៉ែត្រ ស្រាប់តែឈ្មោះ [redacted] សុវណ្ណា, [redacted] យ៉ាវ និង [redacted] ដាយូសា ជិះម៉ូតូមួយគ្រឿងម៉ាកយ៉ាម៉ាហាពណ៌សំបកឪឡឹកគ្មានស្លាកលេខ មកអែបទន្ទឹម [redacted] វណ្ណា ដកអាវុធខ្លីភ្ជង់គំរាមប្លន់យកកាបូប ពេលនោះឈ្មោះ [redacted] គន្ធា ផ្តួលម៉ូតូកាន់កាបូបរត់ទៅក្លោងទ្វារអាផ្ទាធរជាតិកំចាត់មីន ជនល្មើសក៏បាញ់មួយគ្រាប់ បណ្តាលឲ្យត្រូវឈ្មោះ [redacted] ស៊ុ ដែលកំពុងជិះម៉ូតូ ត្រូវពោះខាងស្តាំ(បៀមគ្រាប់) រួចជនល្មើសគេចខ្លួនបាត់។ លុះដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង២២ ឈ្មោះ [redacted] វណ្ណា ឃើញកំលាំងល្បាតព្រយាមគេច សមត្ថកិច្ចសង្ស័យបានឃាត់ខ្លួនសាកសួរ ជនល្មើសក៏សារភាពថា ខ្លួន, [redacted] យ៉ាវ និង [redacted] ដាយូសា ពិតជាបានប្លន់កាបូប កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ម៉ោង៦ និង៣០នាទី ពិតមែន ឯអាវុធខ្លីយកទៅលាក់ទុកនៅក្នុងទូខោអាវក្នុងបន្ទប់ផ្ទះជួលខ្លួន, ក្រោយមកប៉ូលីសដកហូតអាវុធខ្លីម៉ាកកា៥៩ បង់១ និងគ្រាប់៥គ្រាប់, បានឃាត់ខ្លួនជនល្មើស ចំណែកឈ្មោះ [redacted] យ៉ាវ គេចខ្លួនបាត់។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៥២ កប៣ «ដ» ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១. ផ្តន្ទាទោសឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ដាយូសា ហៅ បូ ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗ សរុបកំណត់ ៦ (ប្រាំមួយ) ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗ ចំនួន ៥០.០០០(ហាសិបម៉ឺន) រៀល ដាក់ចូលថវិការដ្ឋ ពីបទ ប៉ុនប៉ងប្លន់ និងបទ ប្រើប្រាស់អាវុធហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ។

២. ផ្តន្ទាទោសឈ្មោះ [redacted] យ៉ាវ ហៅ យួន ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារ ...

សរុបកំណត់៣(បី)ឆ្នាំ គិតពីថ្ងៃចាប់ឃុំខ្លួនបាន និងពិន័យជាប្រាក់ចំនួន៥០.០០០(ហាសិបម៉ឺន)រៀល ដាក់ចូលថវិការដ្ឋ ពីបទ ប៉ុនប៉ងប្លន់ និងបទ ប្រើប្រាស់អាវុធហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ។

៣. បង្គាប់ឲ្យអាណាព្យាបាលរបស់ឈ្មោះ [redacted] យ៉ាវ ហៅ យូន និងឈ្មោះ [redacted] យ៉ាវ ហៅ យូន រួមគ្នាបង់ប្រាក់ពិន័យចំនួន ៥០.០០០ (ហាសិបម៉ឺន) រៀល ដាក់ចូលក្នុងថវិការដ្ឋ ពីបទ ប្រើប្រាស់អាវុធហាមឃាត់ខុសច្បាប់ ខាងលើនេះ។

៤. ទុកសិទ្ធិឲ្យជនរងគ្រោះ [redacted] ស៊ី ហៅ យាយង៉ា ប្តឹងទាមទារសំណងរដ្ឋប្បវេណីពីជនជាប់ចោទទាំងបីនាក់នៅពេលក្រោយ។

៥. វត្ថុតាងក្នុងកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលបានទទួល និងចុះបញ្ជីលេខ ១៧១ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ រួមមានៈ អាវុធខ្លីមួយដើម ម៉ាកកា៥៩ បង់ចំនួនមួយ និងគ្រាប់ចំនួន៥(ប្រាំ)គ្រាប់ ផលិតនៅប្រទេសសូវៀត និងម៉ូតូមួយគ្រឿង ម៉ាកYAMAHA TAURUS សេរី២០០៩ ពណ៌សំបកឪឡឹកចាស់ លេខតួ៩៤០៤៤១០៧ លេខម៉ាស៊ីន០៤៤១០១ គ្មានស្លាកលេខ អត់កញ្ចក់ បែកកុងទ័រ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

៦. សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វណ្ណា, ឈ្មោះ [redacted] ដាយូសា និងមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] យ៉ាវ, ជនរងគ្រោះឈ្មោះ [redacted] ស៊ី និងជនរងគ្រោះឈ្មោះ [redacted] តន្ទា។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៧៦៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ដាយូសា ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៥២ កប៣ «ដ» ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សា សង្ខេបអង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជី អានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ី និងចម្លើយជនរងគ្រោះឈ្មោះ [redacted] គន្ធា បានឆ្លើយនៅ សាលាដំបូងរាជធានីភ្នំពេញ,

ជនជាប់ចោទឈ្មោះ [redacted] ដាយុសា ឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ដើម្បីសុំឲ្យសាលាឧទ្ធរណ៍បន្ធូបន្ថយទោសឲ្យខ្លួន, ខ្លួនសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តដូចមានក្នុងអង្គហេតុមែន, សំណូមពរ សុំបន្ធូបន្ថយ ទោសឲ្យខ្លួន។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ជនជាប់ចោទគាត់បានសារភាពទទួលស្គាល់នូវកំហុសរបស់គាត់ គាត់ប្តឹងឧទ្ធរណ៍មកនេះ សុំឲ្យក្រុមប្រឹក្សាពិចារណាលើទោសរបស់គាត់ សូមក្រុមប្រឹក្សាពិចារណា និងសម្រេចតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

សុំលោកប្រធានក្រុមប្រឹក្សាពិនិត្យ និងសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន តាមមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ដោយគាត់បានសារភាពតាំងពីសាលាដំបូងរហូតមក។

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិចារណា វែកញែក ល្អិតល្អន់តាមច្បាប់រួច

## សភាព្រហ្មទណ្ឌ

## យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍លេខ ៧៦៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ របស់ឈ្មោះ សេន ដាយុសា ជាជនជាប់ចោទ ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,

២. តាមចម្លើយជនជាប់ចោទថា កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ខ្លួន និងបក្សពួក មានឈ្មោះ [redacted] វណ្ណា និង [redacted] យ៉ាវ បានជិះម៉ូតូមួយគ្រឿងរួមគ្នាដោយខ្លួនជាអ្នកបើកម៉ូតូ [redacted] យ៉ាវ ជិះកណ្តាល [redacted] វណ្ណា ជិះក្រោយ។ ពេលធ្វើសកម្មភាព ខ្លួនបើកម៉ូតូកៀរនារីរងគ្រោះដួល, [redacted] យ៉ាវ និង [redacted] វណ្ណា ដេញដណ្តើមកាបូបពីនារីរងគ្រោះ ធ្វើឲ្យនារីរងគ្រោះដួលម្តងទៀត ហើយដើបរត់ ស្រាប់តែឮស្នូរកាំភ្លើងផ្ទុះមួយគ្រាប់ តែមិនដឹងអ្នកណាបាញ់ទេ។

- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] វណ្ណា ថា ពេលធ្វើសកម្មភាពនោះ ខ្លួនដកកាំភ្លើងកា៥៩ បាញ់ទៅលើជនរងគ្រោះ តែមិនត្រូវ ហើយទៅត្រូវអ្នកផ្សេងវិញ។ ៩

៣. មានភស្តុតាងបញ្ជាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទ លួចដោយហិង្សា និងប្រើប្រាស់អាវុធហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ។, ដូច្នេះ គួរកែប្រែបទចោទ ត្រង់បទប្លន់ឡើងវិញ។

៤. សាលក្រមព្រហ្មទណ្ឌលេខ ១៥២ កប៣ «ដ» ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែបទចោទ ពីបទប្លន់ ក្នុងចំណុចទី១ លើជនជាប់ចោទឈ្មោះ [redacted] ជាយូសា គួរកែប្រែ ដូចយល់ឃើញខាងលើ ក្រៅពីនេះគួររក្សាទុកនៅដដែល។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ៧៦៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ជាយូសា ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់,

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៥២ កប៣ «ដ» ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែបទចោទប្រកាន់ពីបទប្លន់ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ត្រូវកែប្រែជា បទលួចដោយហិង្សា តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ វិញ, ក្រៅពីនេះរក្សាទុកនៅដដែល។

៣. បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ, បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ ៥**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

.................................................................................................................

| បានឃើញ | ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
|---|---|
| **ប្រធានសាលាឧទ្ធរណ៍** | ភ្នំពេញ, ថ្ងៃទី 04 ខែ 06 ឆ្នាំ២០១៤ |
| | **ក្រឡាបញ្ជី** |